# ប្រសិនបើលោកអ្នកជឿជាក់ថា លោកអ្នកកំពុងស្ថិតនៅក្នុងវិបត្តិ ប្រព័ន្ធកំដៅនោះ សូមទាក់ទង ការិយាល័យជំនួយនៅខោនធីនៅ មូលដាន(CAO) របស់អ្នក។

បញ្ជីការិយាល័យជំនួយនៅខោនធី CAOs និងព័ត៌មានដែលមានប្រយោជន៍ផ្សេងៗទៀត អាចរកបានតាមវិបសាយ៖

https://www.dhs.pa.gov/Services/Assistance/Pages/LIHEAP.aspx

ប្រសិនបើលោកអ្នករស់នៅខោនធីដូចខាងក្រោមនេះ សូមទាក់ទងអ្នកម៉ៅការផ្នែកវិបត្តិរបស់អ្នក៖

**Luzerne**
**(800) 822-0359**

**Wyoming**
**(570) 836-4090**

COMPASS
CLICK. APPLY. BENEFIT.

## លេខទូរស័ព្ទទាន់ហេតុការណ៍ ដោយឥតគិតថ្លៃនៅទូទាំងរដ្ឋ

**1-866-857-7095**

## ខោនធីទីក្រុង Philadelphia County ទូរស័ព្ទលេខ

**(215) 560-1583**

បុគ្គលនានាដែលថ្លង់ ពិបាកស្តាប់ ឬមានពិការភាពក្នុងការនិយាយ និងមាន បំណងទាក់ទងជាមួយ បណ្តាញទូរស័ព្ទជំនួយ អាចហៅទូរស័ព្ទទៅ សេវាកម្មបញ្ជូនបន្ត ( PA Relay Services ) ដោយចុចលេខ 711 ។

សូមដាក់ពាក្យសុំតាមអ៊ីនធឺណិតតាមវិបសាយ៖

**www.compass.state.pa.us**

ពាក្យសុំនានាក៏អាចរកបានផងដែរនៅឯការិយាល័យ ជំនួយនៅខោនធីនៅមូលដ្ឋានរបស់អ្នក។

pennsylvania
DEPARTMENT OF HUMAN SERVICES

HSEA 18-C 9/21

ប្រសិនបើលោកអ្នកត្រូវការ ជំនួយបង់ប្រាក់វិក្កយបត្រ ប្រព័ន្ធកំដៅរបស់អ្នក ឬ មានការជំនួយបន្ទាន់ផ្នែកប្រព័ន្ធកំដៅ ប្រព័ន្ធកំដៅ...

# កម្មវិធី LIHEAP អាចជួយលោកអ្នក

LIHEAP
Low-Income Home Energy Assistance Program

**Important Information about an Energy Assistance Program**

ពត៌មានសំខាន់អំពីជំនួយលើថ្លៃ ភ្លើងនិងហ្គែស (ENERGY ASSISTANCE PROGRAM) ។

Información importante sobre un programa de asistencia para el pago de energía

关于能源补助计划的重要消息

Thông báo quan trọng về chương trình trợ giúp năng lượng

معلومات مهمة حول برنامج معونة الطاقة

Важная информация о программе помощи в оплате счетов за електро- энергию.

## តើ LIHEAP ជាអ្វី?

កម្មវិធីជំនួយថាមពលតាមផ្ទះដែលមានប្រាក់ចំណូលទាប (LIHEAP) ជួយក្រុមគ្រួសារដែលមានប្រាក់ចំណូលទាបបង់ប្រាក់វិក្កយបត្រប្រព័ន្ធកំដៅរបស់ពួកគេ។ កម្មវិធី LIHEAP គឺជាជំនួយឥតសំណង។ លោកអ្នកមិនចំបាច់ផ្តល់សំណងវិញទ្បើយទ្បើយ។

### ដើម្បីទទួលបានជំនួយ...

- សូមដាក់ពាក្យសុំនៅរវាងថ្ងៃទី 1 ខែវិច្ឆិកា ឆ្នាំ 2021 និងថ្ងៃទី 6 ឧសភា ឆ្នាំ 2022 ។
- លោកអ្នកមិនចាំបាច់មានជំនួយរដ្ឋទ្បើយ
- លោកអ្នកមិនចាំបាច់មានវិក្កយបត្រប្រព័ន្ធកំដៅដែលមិនបានបង់ប្រាក់ទ្បើយ
- លោកអ្នកអាចជួលផ្ទះ ឬអាចមានកម្មសិទ្ធិផ្ទះរបស់អ្នក

## តើកម្មវិធី LIHEAP មានដំណើរការយ៉ាងដូចម្តេច?

កម្មវិធី LIHEAP ផ្តល់ជូនទាំងជំនួយជាសាច់ប្រាក់ និងជំនួយពេលមានវិបត្តិ។ ក្រុមគ្រួសារ អាចដាក់ពាក្យសុំ៖

### ជំនួយជាសាច់ប្រាក់

ជំនួយជាសាច់ប្រាក់ ជួយក្រុមគ្រួសារបង់ប្រាក់វិក្កយបត្រប្រព័ន្ធកំដៅរបស់ពួកគេ។ ការទូទាត់មួយលើក ត្រូវបានបញ្ជូនដោយផ្ទាល់ទៅក្រុមហ៊ុនបម្រើសេវាប្រើប្រាស់ប្រចាំថ្ងៃ ឬក្រុមហ៊ុនផ្គត់ផ្គង់ប្រេងឥន្ធនៈរបស់អ្នក ហើយការទូទាត់និងត្រូវបានទទួលនៅក្នុងវិក្កយបត្ររបស់អ្នក។ (ក្នុងករណីខ្លះការត្រួតពិនិត្យនេះ អាចត្រូវផ្ញើទៅលោកអ្នកដោយផ្ទាល់។) ជំនួយឥតសំណងជាសាច់ប្រាក់មានចាប់ពី $500-$1500 ដុល្លារ ដោយផ្អែកលើទំហំគ្រួសារ ប្រាក់ចំណូល និងប្រភេទប្រេងឥន្ធនៈ។

### ជំនួយពេលមានវិបត្តិ

ជំនួយពេលមានវិបត្តិ អាចមានប្រសិនបើលោកអ្នកស្ថិតក្នុងស្ថានភាពអាសន្ន និងមានគ្រោះថ្នាក់នៃការបាត់បង់ប្រព័ន្ធកំដៅរបស់អ្នក។ លោកអ្នកអាចទទួលបានជំនួយពេលមានវិបត្តិច្រើនជាងមួយក្នុងករណីចាំបាច់ នៅកំឡុងពេលសមស្របតាមតាមរដូវកាល រហូតដល់កម្រិតនៃការធានារ៉ាប់រងអតិបរមា $1200 ដុល្លារ។

### ស្ថានភាពមានវិបត្តិ រួមមាន៖

- ឧបករណ៍ប្រព័ន្ធកំដៅខូច ឬបណ្តាញលេចធ្លាយ ដែលត្រូវជួសជុល ឬដាក់ជំនួសវិញ
- កង្វះខាតប្រេងឥន្ធនៈ
- ការបញ្ឈប់សេវាប្រើប្រាស់ប្រចាំថ្ងៃ
- គ្រោះថ្នាក់ពីការគ្មានប្រេងឥន្ធនៈ (ការផ្គត់ផ្គង់តិចជាង 15 ថ្ងៃ) ឬមានសេវាប្រើប្រាស់ប្រចាំថ្ងៃដែលបានបញ្ឈប់ (បានទទួលលិខិតជូនដំណឹងថា ការបម្រើសេវាកម្មនឹងត្រូវបិទដំណើរការក្នុងរយៈពេល 60 ថ្ងៃក្រោយ)

ប្រសិនបើលោកអ្នកមានបញ្ហាអាសន្នប្រព័ន្ធកំដៅ សូមហៅទូរស័ព្ទរបស់ LIHEAP ការិយាល័យជំនួយនៅខោនធីនៅមូលដ្ឋាន (CAO) របស់អ្នក។

## តើខ្ញុំត្រូវដាក់ពាក្យសុំដោយរបៀបណា?

- សូមដាក់ពាក្យសុំតាមអ៊ីនធឺណិតតាមវិបសាយ៖ www.compass.state.pa.us
- ស្នើសុំពាក្យសុំតាមរយៈការហៅទូរស័ព្ទទាន់ហេតុការណ៍របស់ LIHEAP នៅទូទាំងរដ្ឋ (Statewide LIHEAP Hotline) តាមទូរស័ព្ទលេខ 1-866-857-7095 ឬហៅទូរស័ព្ទទៅសេវាកម្មបញ្ជូនបន្ត (PA Relay) តាមទូរស័ព្ទលេខ 711 សម្រាប់អ្នកដែលមានពិការភាពខាងស្តាប់។
- ពាក្យសុំនានាអាចរកបាននៅការិយាល័យ CAO ក្នុង មូលដ្ឋានរបស់អ្នក

### ដើម្បីដាក់ពាក្យសុំ លោកអ្នកត្រូវការ

- ឈ្មោះអ្នករស់នៅក្នុងគ្រួសាររបស់អ្នក
- ថ្ងៃខែឆ្នាំកំណើតសមាជិកគ្រួសារទាំងអស់
- លេខសន្តិសុខសង្គមរបស់សមាជិកគ្រួសារទាំងអស់
- លិខិតបញ្ជាក់អំពីប្រាក់ចំណូលរបស់សមាជិកគ្រួសារទាំងអស់
- វិក្កយបត្រប្រព័ន្ធកំដៅថ្មី

## តើនរណាជាអ្នកមានសិទ្ធិស្របច្បាប់?

លោកអ្នកអាចមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ចំពោះជំនួយពីកម្មវិធី LIHEAP ប្រសិនបើប្រាក់ចំណូលគ្រួសាររបស់អ្នក បំពេញតាមគោលការណ៍ណែនាំអំពីប្រាក់ចំណូលដូចខាងក្រោម៖

### គោលការណ៍ណែនាំអំពីប្រាក់ចំណូល 2021 - 2022 LIHEAP

| ទំហំគ្រួសារ | ប្រាក់ចំណូលប្រចាំឆ្នាំអតិបរមា |
|---|---|
| 1 | $ 19,320 |
| 2 | $ 26,130 |
| 3 | $ 32,940 |
| 4 | $ 39,750 |
| 5 | $ 46,560 |
| 6 | $ 53,370 |
| 7 | $ 60,180 |
| 8 | $ 66,990 |
| 9 | $ 73,800 |
| 10 | $ 80,610 |

បុគ្គលដែលបញ្ជូនបន្ថែមម្នាក់ៗ $ 6,810

បន្ទាប់ពីការដាក់ពាក្យសុំរបស់អ្នកត្រូវបានដំណើរការ លោកអ្នកនឹងទទួលបានលិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរដែលនឹងប្រាប់លោកអ្នកថាតើលោកអ្នកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែរឬទេ។ ប្រសិនបើមានសិទ្ធិស្របច្បាប់នោះ លិខិតជូនដំណឹងនេះ នឹងប្រាប់លោកអ្នកអំពីចំនួនប្រាក់ជំរបស់អ្នក។